ភ្នំពេញ , ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៣

## អនុក្រឹត្យលេខ ០៦ អនក្រ ស្ដីពីការ
## ផ្ទេរសមត្ថកិច្ចចេញលិខិតឆ្លងដែនប្រជាពលរដ្ឋ
## មកក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

* * *

- យោងតាមព្រះរាជក្រឹត្យ របស់សម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងតាមសេចក្ដីស្នើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ លេខ ៣២៧១ កស .ការទ ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៣
- យោងតាមការឯកភាពរបស់ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ លេខ ០២៦ ក្រស. មផ.សជ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៣

### សំរេច

មាត្រា ១ : ផ្ទេរសមត្ថកិច្ច ចេញលិខិតឆ្លងដែនប្រជាពលរដ្ឋពី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មកក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ។

មាត្រា ២ : បទបញ្ញត្តិទាំងអស់ពីមុនដែលផ្ទុយ និង អនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ត្រូវទទួលភារកិច្ចចាត់ការអោយបានសំរេចតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និង ចុះហត្ថលេខានេះតទៅ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា

ព្រះហស្ដលេខា និង ត្រា | ហត្ថលេខា និង ត្រា

ស្ដេចក្រុមហ្លួង នរោត្តម រណឫទ្ធិ | ហ៊ុន សែន